# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ សសរ

## សេចក្ដីសំរេច
## ស្ដីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/៨៤ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្ដម **សេខ ទាំឡាត់** ទីប្រឹក្សាផ្ទាល់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ស ខេង) ឱ្យទទួលការងារតាមដានការអនុវត្តន៍ការងារគ្រប់វិស័យ នៅខេត្តបាត់ដំបង ។

**ប្រការ ២ :** ឯកឧត្ដម **សេខ ទាំឡាត់** ត្រូវរាយការណ៍អំពីសភាពការណ៍លេចធ្លោ បញ្ហាប្រឈម និងសំណូមពរនានានៅខេត្តបាត់ដំបង ព្រមទាំងវិធានការដោះស្រាយ ជូនឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **ស ខេង** ឱ្យបានជាប្រចាំ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អភិបាលខេត្តបាត់ដំបង និងឯកឧត្ដម **សេខ ទាំឡាត់** ត្រូវអនុវត្តសេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញៈថ្ងៃទី ០៣ ខែ ០៣ ឆ្នាំ ២០០៦

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ